ព្រះរាជក្រម

នស/រកម/១១២០/ ០៧៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

## ស្ដីពី

# ការគ្រប់គ្រង ការប្រើប្រាស់
# និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះ មានគោលបំណងគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព សង្គតិភាព នីត្យានុកូលភាព បូរណភាព និងចីរភាព ដោយកំណត់ក្របខ័ណ្ឌច្បាប់និងស្ថាប័នជាគោល សំដៅចូលរួមចំណែកបម្រើឧត្តមប្រយោជន៍នៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទ ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតនៅក្រោមអធិបតេយ្យភាពនិង/ឬយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។

ការគ្រប់គ្រង ការការពារ ការប្រើប្រាស់ ការអភិរក្ស និងការអភិវឌ្ឍធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋរបស់ធនាគារជាតិនៃកម្ពុជា ត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា។

**មាត្រា៣ .-**

បច្ចេកសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យកំណត់ក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## អំពីទ្រព្យសម្បត្តិរដ្ឋ
### ផ្នែកទី១
### ប្រភពនៃទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៤ .-**

ទ្រព្យសម្បត្តិរដ្ឋ មានប្រភពមកពីទ្រព្យសម្បត្តិទាំងឡាយ ដែលកើតឡើងតាមធម្មជាតិ ឬបង្កើតឡើងដោយមនុស្សជាតិ ក្រោមទម្រង់ជាចលនទ្រព្យ ឬអចលនទ្រព្យ រូបី ឬអរូបី ដែលមិនមែនជាកម្មសិទ្ធិឯកជន។

**មាត្រា៥ .-**

ទ្រព្យសម្បត្តិរដ្ឋដោយធម្មជាតិ ជាទ្រព្យសម្បត្តិរបស់រដ្ឋ ដែលកើតឡើងតាមធម្មជាតិ មានជាអាទិ៍ ដីធ្លី ទឹក ខ្យល់ អាកាស កោះ សមុទ្រ បាតសមុទ្រ ធនធានក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ ភ្នំ ជ្រោះភ្នំ ព្រៃឈើ ទន្លេ ព្រែក ស្ទឹង បឹង រ៉ែគ្រប់ប្រភេទ ប្រភពទឹក ធនធានជលផល ធនធានព្រៃឈើ និងប្រភពធនធានធម្មជាតិផ្សេងៗទៀតដែលឋិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនដីគោក ដែនទឹក និងដែនអាកាស ព្រមទាំងធនធានធម្មជាតិដទៃទៀត ដែលស្ថិតនៅក្រោមអធិបតេយ្យភាព និង/ឬយុត្តាធិការ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦ .-**

ទ្រព្យសម្បត្តិរដ្ឋដោយមនុស្សជាតិ ជាទ្រព្យសម្បត្តិរដ្ឋ ដែលបង្កើតឡើងដោយអំពើរបស់មនុស្ស មានជាអាទិ៍៖

ក- ទ្រព្យសម្បត្តិដែលជាបេតិកភណ្ឌវប្បធម៌ សំណង់ប្រវត្តិសាស្ត្រ រមណីយដ្ឋានប្រវត្តិសាស្ត្រ សំណង់សាសនា វត្តអារាម សិលាចារឹក មូលដ្ឋានការពារប្រទេស។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៥. ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈលទ្ធកម្មនៃកម្មសិទ្ធិ មកជាទ្រព្យសម្បត្តិរដ្ឋ ដោយប្រើប្រាស់ ឬមិនប្រើប្រាស់ថវិការដ្ឋ មានជាអាទិ៍ ការទិញ ការដូរ អស្សាមិករណ៍ ប្រទានកម្ម អច្ច័យទាន ទ្រព្យនិទាឃាទ ទ្រព្យគ្មានម្ចាស់គ្រប់គ្រង ការរឹបអូសដោយសេចក្ដីសម្រេចស្ថាពររបស់តុលាការ ព្រមទាំងទ្រព្យសម្បត្តិដែលរដ្ឋទទួលបានដោយមធ្យោបាយស្របច្បាប់ផ្សេងទៀត។

## ផ្នែកទី២
## ប្រភេទទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៧ .-**

ទ្រព្យសម្បត្តិរដ្ឋ ចែកចេញជា៖

- ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈដទៃទៀត
- ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងទ្រព្យសម្បត្តិឯកជនរបស់នីតិបុគ្គលសាធារណៈដទៃទៀត។

**មាត្រា៨ .-**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ជាប្រយោជន៍សាធារណៈ ឬជាប្រយោជន៍ក្នុងការបម្រើសេវាសាធារណៈ។

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាទ្រព្យសម្បត្តិដែលមិនស្ថិតក្នុងប្រភេទទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនមានលក្ខណសម្បត្តិក្នុងការបម្រើប្រយោជន៍សាធារណៈ លែងជាប្រយោជន៍ក្នុងការបម្រើសេវាសាធារណៈ មិនមែនជាការប្រើប្រាស់ដោយផ្ទាល់ដោយសាធារណជន និងមិនស្ថិតក្នុងប្រភេទកម្មសិទ្ធិឯកជន មានជាអាទិ៍៖

១. ទ្រព្យសម្បត្តិ ដែលបានធ្វើចំណាត់ថ្នាក់ឡើងវិញពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈការធ្វើអនុប្បយោគ ដូចមានចែងក្នុងមាត្រា២៧នៃច្បាប់នេះ។

២. ទ្រព្យសម្បត្តិ ដែលទទួលបានពីការទិញ ការដូរ ប្រទានកម្ម អច្ច័យទាន ទ្រព្យនិទាឃាទ ទ្រព្យគ្មានម្ចាស់គ្រប់គ្រង ទ្រព្យរឹបអូសដោយសេចក្ដីសម្រេចស្ថាពររបស់តុលាការ សម្បទានដីសេដ្ឋកិច្ច។

៣. ទ្រព្យសម្បត្តិដទៃទៀត ដែលកំណត់ថាជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

**មាត្រា៩ .-**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋរួមមាន ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋជាអចលនទ្រព្យនិងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋជាចលនទ្រព្យ។

**មាត្រា១០ .-**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋជាអចលនទ្រព្យ គឺជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ជាប្រយោជន៍សាធារណៈឬជាប្រយោជន៍ក្នុងការបម្រើសេវាសាធារណៈ ដែលរួមមានជាអាទិ៍៖

១. ទ្រព្យទាំងឡាយដែលកើតឡើងតាមធម្មជាតិ ជាអាទិ៍ ធនធានជលផល ធនធានព្រៃឈើ ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្ដោតបាន បឹងធម្មជាតិ ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្ដោតបាន ឆ្នេរសមុទ្រ ដែនអាកាស ព្រែក អូរ បឹង កោះ កូនកោះ និងតំបន់ដីដែលលិចទឹកអចិន្ត្រៃយ៍។

២. ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈ ជាអាទិ៍ តំបន់ កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ។

៣. ទ្រព្យទាំងឡាយដែលដាក់ឱ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ជាអាទិ៍ ផ្លូវថ្នល់ ផ្លូវលំ ឧទ្យាន រមណីយដ្ឋានធម្មជាតិ ដីចំណី និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ជាអាទិ៍ សាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈ។

៥. ទ្រព្យទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិការពារដោយច្បាប់។

៦. បេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌបុរាណវិទ្យា បុរាណស្ថាន រមណីយដ្ឋានវប្បធម៌និងប្រវត្តិសាស្ត្រ សំណង់ប្រវត្តិសាស្ត្រ។

៧. អចលនទ្រព្យផ្សេងទៀត ដែលជាកម្មវត្ថុនៃការប្រើប្រាស់ជាប្រយោជន៍សាធារណៈ ឬសេវាសាធារណៈ ឬកំណត់ដោយបទប្បញ្ញត្តិគតិយុត្តជាធរមាន។

**មាត្រា១១ .-**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋជាចលនទ្រព្យ គឺជាទ្រព្យសម្បត្តិ ដែលមានលក្ខណៈជាប្រយោជន៍សាធារណៈ ដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ សិល្បៈ បូរាណវិទ្យា វិទ្យាសាស្ត្រ ឬបច្ចេកវិទ្យា ជាអាទិ៍ សិលាចារឹក សាស្ត្រាស្លឹករឹត បណ្ណសារ សមុច្ច័យ។

## ផ្នែកទី៣
## របបគតិយុត្តនៃទ្រព្យសម្បត្តិរដ្ឋ

**មាត្រា១២ .-**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ពុំអាចជាកម្មវត្ថុនៃការលក់ ដូរ ការដាក់ប្រាតិភោគ ប្រទានកម្ម អច្ច័យទាន សម្បទានដី រឹបអូស និងពុំមានអាជ្ញាយុកាល។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ អាចជាកម្មវត្ថុនៃការជួល ការធ្វើសម្បទានហេដ្ឋារចនាសម្ព័ន្ធ និងសម្បទានគ្រប់គ្រងសេវាសាធារណៈ លើកលែងតែទ្រព្យសម្បត្តិ ដែលមានលក្ខណៈជាបេតិកភណ្ឌវប្បធម៌ជាតិ។

វិធាននិងនីតិវិធីនៃការជួល ការធ្វើសម្បទានហេដ្ឋារចនាសម្ព័ន្ធ និងសម្បទានគ្រប់គ្រងសេវាសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលបាត់បង់ផលប្រយោជន៍សាធារណៈ ឬលែងជាកម្មវត្ថុនៃការបម្រើសេវាសាធារណៈ អាចក្លាយជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដោយអនុលោមតាមនីតិវិធីនៃការធ្វើអនុប្បយោគ ដូចមានចែងក្នុងផ្នែកទី៤ នៃជំពូកទី៤នៃច្បាប់នេះ។

**មាត្រា១៣ .-**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុនៃការចាត់ចែង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

# ជំពូកទី៣
# ក្របខ័ណ្ឌស្ថាប័ន
## ផ្នែកទី១
## អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា១៤ .-**

រាជរដ្ឋាភិបាល មានសមត្ថកិច្ចគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នៅក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន។

**មាត្រា១៥ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល លើការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- សម្របសម្រួល ជំរុញ និងណែនាំដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ផ្សព្វផ្សាយ ណែនាំ និងជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ
- ពិនិត្យនិងផ្តល់យោបល់លើការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច
- ត្រួតពិនិត្យ ធ្វើសវនកម្ម និង/ឬអធិការកិច្ចលើការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ
- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋជូននាយករដ្ឋមន្ត្រី
- ដឹកនាំដោះស្រាយបញ្ហាពាក់ព័ន្ធការរំលោភបំពានលើទ្រព្យសម្បត្តិរដ្ឋ ដោយរាយការណ៍ជូននាយករដ្ឋមន្ត្រី។

## ផ្នែកទី២
## អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ

**មាត្រា១៦ .-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដទៃទៀត ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ តាមបទប្បញ្ញត្តិគតិយុត្តជាធរមាន ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងការទទួលខុសត្រូវ នៅចំពោះមុខអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងរាជរដ្ឋាភិបាល
- រៀបចំចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមបញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួន ដើម្បីដាក់ជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យបានត្រឹមត្រូវស្របតាមបញ្ញត្តិគតិយុត្តជាធរមាន
- រៀបចំរបាយការណ៍វឌ្ឍនភាពនិងបញ្ហាប្រឈមនៃការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិនិត្យនិងដោះស្រាយ
- ចាត់ចែងធ្វើសវនកម្មផ្ទៃក្នុងតាមការដាក់ស្នែងលើការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ តាមការស្នើសុំពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- លើកសំណើសុំចាត់ចែងនិងជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឬរាជរដ្ឋាភិបាល
- ពិនិត្យនិងដោះស្រាយបញ្ហាពាក់ព័ន្ធការរំលោភបំពានលើទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតក្រោមការកាន់កាប់។

## ជំពូកទី៤
## ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
## ផ្នែកទី១
## ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

**មាត្រា១៧ .-**

ទ្រព្យសម្បត្តិរដ្ឋ ត្រូវចុះបញ្ជីនៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមវិធាននិងនីតិវិធី ដែលកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះរាជដំណាក់

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងទ្រព្យសម្បត្តិដែលទទួលបានពីហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ហិរញ្ញប្បទានថវិកាជាតិ និងហិរញ្ញប្បទានពីគម្រោងវិនិយោគភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។

## ផ្នែកទី២
## វិធាននិងនីតិវិធីនៃការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ

### មាត្រា១៨ .-

ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានប្រគល់ឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវកាន់កាប់និងប្រើប្រាស់ ដោយអនុលោមតាមប្រភេទនៃទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាកិច្ចដំណើរការការងារជាផលប្រយោជន៍សាធារណៈ និង/ឬសេវាសាធារណៈក្រោមសមត្ថកិច្ចនៃស្ថាប័នរបស់ខ្លួន។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវកាន់កាប់និងប្រើប្រាស់ ដោយអនុលោមតាមគោលបំណងនៃការបម្រើប្រយោជន៍សាធារណៈឬសេវាសាធារណៈ ដោយត្រូវមានលក្ខណៈបណ្ដោះអាសន្ន មិនទៀង និងអាចដកហូតវិញបាន។

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវកាន់កាប់និងប្រើប្រាស់ ដោយអនុលោមតាមវិធាននិងនីតិវិធី ដែលអនុវត្តចំពោះទ្រព្យនោះ។

### មាត្រា១៩ .-

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលត្រូវបានប្រគល់ឱ្យបុគ្គលឯកជនតាមរយៈការជួល សម្បទាន ហេដ្ឋារចនាសម្ព័ន្ធ ឬសម្បទានគ្រប់គ្រងសេវាសាធារណៈ មិនត្រូវបង្កឧបសគ្គដល់គោលបំណងនៃការបម្រើប្រយោជន៍សាធារណៈឬសេវាសាធារណៈ។

ការកាន់កាប់និងការប្រើប្រាស់ លើដីក្នុងតំបន់ការពារធម្មជាតិឬក្នុងតំបន់ដីព្រៃឈើគ្រប់ប្រភេទ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវមានការឯកភាពជាមុន ពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

### មាត្រា២០ .-

អ្នករាជការសាធារណៈ ដែលជាអ្នកបម្រើសេវាសាធារណៈ អាចត្រូវបានអនុញ្ញាតឱ្យស្នាក់នៅជាបណ្ដោះអាសន្នក្នុងគេហដ្ឋានឬអគារស្នាក់នៅ ដែលជាទ្រព្យសម្បត្តិរដ្ឋ ដោយត្រូវដកហូតវិញនៅពេលបញ្ចប់ពីមុខតំណែង។

បែបបទនិងលក្ខខណ្ឌនៃការអនុញ្ញាតឱ្យស្នាក់នៅនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### មាត្រា២១ .-

អ្នករាជការសាធារណៈ ដែលត្រូវបានអនុញ្ញាតឱ្យកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដែលជាចលនទ្រព្យនឹងត្រូវដកហូតវិញនៅពេលបញ្ចប់ពីមុខតំណែង។

បែបបទនិងលក្ខខណ្ឌនៃការអនុញ្ញាតឱ្យកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដែលជាចលនទ្រព្យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### មាត្រា២២ .-

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលបានទទួលសិទ្ធិកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ត្រូវមានកាតព្វកិច្ចថែរក្សានិងកែលម្អទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាមិនឱ្យបាត់បង់ឬខូចខាត ដោយត្រូវរក្សាទាំងបរិមាណនិងគុណភាពនៃទ្រព្យសម្បត្តិទាំងនោះ ឱ្យបានល្អតាមបទដ្ឋានបច្ចេកទេស លើកលែងតែការសឹករេចខូចខាតឬករណីប្រធានសក្តិ។

[illegible]ណីទ្រព្យសម្បត្តិរដ្ឋទាំងនោះបាត់បង់ឬថយចុះតម្លៃ មិនអាចប្រើប្រាស់បានឬប្រើប្រាស់មិនបានយូរ ត្រូវ[illegible]បញ្ជីចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី៨ ជំពូកទី៦ [illegible]នេះ។

**មាត្រា២៣ ._**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលបានទទួលសិទ្ធិកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ត្រូវមានកាតព្វកិច្ចថែរក្សាការពារ អភិរក្ស និងអភិវឌ្ឍទ្រព្យសម្បត្តិរដ្ឋឱ្យកាន់តែល្អប្រសើរប្រកបដោយចីរភាព។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំផែនការថវិកាសម្រាប់ការថែរក្សា ការពារ កែលម្អ និងជួសជុលទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតនៅក្រោមការកាន់កាប់និងប្រើប្រាស់របស់ខ្លួន ដោយបញ្ចូលទៅក្នុងគម្រោងចំណាយនៃផែនការថវិកាប្រចាំឆ្នាំ។

## ផ្នែកទី៣
## ការផ្ទេរសិទ្ធិកាន់កាប់និងប្រើប្រាស់

**មាត្រា២៤ ._**

ទ្រព្យសម្បត្តិរដ្ឋ អាចផ្ទេរជូនអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដើម្បីកាន់កាប់និងប្រើប្រាស់ជាប្រយោជន៍នៃការបំពេញមុខងាររបស់ខ្លួន ឬប្រយោជន៍សាធារណៈ ឬបំពេញតម្រូវការសេវាសាធារណៈ។

ការផ្ទេរសិទ្ធិកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាអចលនទ្រព្យ ទៅឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ការផ្ទេរសិទ្ធិកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យ ទៅឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវសម្រេចដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា២៥ ._**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ អាចប្រើប្រាស់និងទទួលយកចំណូលពីទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានផ្ទេរ។ ការលក់ ការដូរ ការជួល និងការផ្ទេរសិទ្ធិប្រើប្រាស់បន្ត ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវផ្ទេរមកជាទ្រព្យសម្បត្តិរបស់រដ្ឋវិញ តាមរយៈអនុក្រឹត្យ ឬការសម្រេចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅពេលដែលកម្មវត្ថុនៃការផ្ទេរទ្រព្យសម្បត្តិនោះ ត្រូវបានបំពេញឬលែងជាតម្រូវការចាំបាច់សម្រាប់ជាប្រយោជន៍នៃការបំពេញភារកិច្ចរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា២៦ ._**

ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ហិរញ្ញប្បទានថវិកាជាតិ និងហិរញ្ញប្បទានពីគម្រោងវិនិយោគភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន ដែលប្រើប្រាស់សម្រាប់ដំណើរការគម្រោង ឬកម្មវិធីណាមួយ ត្រូវផ្ទេរមកជាទ្រព្យសម្បត្តិរបស់រដ្ឋនៅពេលដែលគម្រោងឬកម្មវិធីទាំងនោះត្រូវបានបញ្ចប់ជាស្ថាពរ។

វិធាននិងនីតិវិធីនៃការផ្ទេរមកជាទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៤
## អនុប្បយោគនិងអធិប្បយោគ

**មាត្រា២៧ ._**

អនុប្បយោគ ជាការធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ចំពោះទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែល៖

- នៅទំនេរ លែងជាតម្រូវការនៃផលប្រយោជន៍សាធារណៈ ឬការផ្តល់សេវាសាធារណៈ
- បាត់បង់លក្ខណសម្បត្តិក្នុងការបម្រើប្រយោជន៍សាធារណៈ
- លែងមានការប្រើប្រាស់ដោយផ្ទាល់ដោយសាធារណជន។

វិធាននិងនីតិវិធីនៃអនុប្បយោគ ត្រូវកំណត់ដោយច្បាប់។

នីតិវិធីលម្អិតនៃការធ្វើអនុប្បយោគ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៨ .‒**

ការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ អាចធ្វើទៅបានតែចំពោះទ្រព្យសម្បត្តិរដ្ឋទាំងឡាយណា ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋរួចហើយ។

**មាត្រា២៩ .‒**

អធិប្បយោគ ជាការធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ មកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ចំពោះទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមានតម្រូវការនៃការបម្រើផលប្រយោជន៍សាធារណៈ ឬការផ្តល់សេវាសាធារណៈ។

វិធាននៃការធ្វើអធិប្បយោគ ត្រូវកំណត់ដោយច្បាប់។

នីតិវិធីលម្អិតនៃការធ្វើអធិប្បយោគ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥

## លទ្ធកម្មនៃកម្មសិទ្ធិមកជាទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៣០ .‒**

លទ្ធកម្មនៃកម្មសិទ្ធិមកជាទ្រព្យសម្បត្តិរដ្ឋ អាចត្រូវបានធ្វើឡើងតាមរយៈកិច្ចសន្យាលក់ទិញ កិច្ចសន្យាដូរ ប្រទានកម្ម អច្ច័យទាន ទ្រព្យនិទាឃាទ ទ្រព្យគ្មានម្ចាស់គ្រប់គ្រង ការអនុវត្តសិទ្ធិពិសេសរបស់រដ្ឋ ការរឹបអូសតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ ឬតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

**មាត្រា៣១ .‒**

ការធ្វើលទ្ធកម្មនៃកម្មសិទ្ធិមកជាទ្រព្យសម្បត្តិរដ្ឋ នូវទ្រព្យសម្បត្តិជាចលនទ្រព្យ តាមរយៈកិច្ចសន្យាលក់ទិញ ត្រូវអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធលទ្ធកម្មសាធារណៈ។

ការធ្វើលទ្ធកម្មនៃកម្មសិទ្ធិមកជាទ្រព្យសម្បត្តិរដ្ឋ នូវទ្រព្យសម្បត្តិជាអចលនទ្រព្យ តាមរយៈកិច្ចសន្យាលក់ទិញ ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣២ .‒**

ការធ្វើលទ្ធកម្មនៃកម្មសិទ្ធិមកជាទ្រព្យសម្បត្តិរដ្ឋ តាមរយៈកិច្ចសន្យាដូរទ្រព្យសម្បត្តិរដ្ឋនិងទ្រព្យសម្បត្តិឯកជន ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកទី២ ជំពូកទី៦នៃច្បាប់នេះ។

**មាត្រា៣៣ .‒**

ការធ្វើលទ្ធកម្មនៃកម្មសិទ្ធិមកជាទ្រព្យសម្បត្តិរដ្ឋ តាមរយៈប្រទានកម្មឬអច្ច័យទាន ត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

វិធាននិងនីតិវិធីនៃការផ្ទេរនិងទទួលមកជាទ្រព្យសម្បត្តិរដ្ឋ តាមរយៈប្រទានកម្មឬអច្ច័យទាន ត្រូវកំណត់ដោយអនុក្រឹត្យ។

ការធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលទទួលបានតាមរយៈហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ហិរញ្ញប្បទានថវិកាជាតិ និងហិរញ្ញប្បទានពីគម្រោងវិនិយោគភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជនមកជាទ្រព្យសម្បត្តិរដ្ឋត្រូវគោរពតាមបែបបទដែលមានកំណត់ក្នុងមាត្រា២៦នៃច្បាប់នេះ។

**មាត្រា៣៤ .‒**

ទ្រព្យនិទាឃាទនិងទ្រព្យគ្មានម្ចាស់គ្រប់គ្រង ត្រូវទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ ដោយអនុលោមតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី។

វិធាននិងនីតិវិធីនៃការផ្ទេរនិងទទួលទ្រព្យនិទាឃាទនិងទ្រព្យគ្មានម្ចាស់គ្រប់គ្រង ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ព្រះបរមរាជវាំង

- បញ្ចាំ ឬប្រាតិភោគ ឬការដាក់ហ៊ីប៉ូតែក

- ការជួលបន្ត

- កម្មវត្ថុនៃសន្តតិកម្ម

- ការចាត់ចែងផ្សេងៗទៀត ដោយយកថ្លៃ ឬដោយឥតគិតថ្លៃ។

ការអនុវត្តសិទ្ធិខាងលើ ត្រូវមានការយល់ព្រមពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនិងអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៤១ .-**

វិធាននិងនីតិវិធីនៃការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២

## ការលក់ឬការដូរទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៤២ .-**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុនៃការលក់ឬការដូរ ក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងភាពទំនេរ ពុំមានការប្រើប្រាស់ឬបាត់បង់ប្រយោជន៍នៃការប្រើប្រាស់ដោយមានកាតព្វកិច្ច ថែរក្សា ការពារ និងអភិវឌ្ឍទ្រព្យសម្បត្តិរដ្ឋស្របតាមច្បាប់នេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា៤៣ .-**

ការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាចលនវត្ថុ ត្រូវសម្រេចដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លើកលែងតែចំពោះចលនវត្ថុដែលមានតម្លៃខ្ពស់ ត្រូវសម្រេចដោយនាយករដ្ឋមន្ត្រី។

ការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាអចលនវត្ថុ ត្រូវសម្រេចដោយនាយករដ្ឋមន្ត្រី។

**មាត្រា៤៤ .-**

ការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវធ្វើឡើងតាមសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យនិងសម្រេច ឬលើកយោបល់សុំការសម្រេចពីនាយករដ្ឋមន្ត្រី។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យនិងវាយតម្លៃទ្រព្យសម្បត្តិរដ្ឋ ដែលមានសមាសភាពពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៤៥ .-**

វិធាននិងនីតិវិធីនៃការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣

## ការទិញ ការលក់ ការដូរ ឬការជួលទ្រព្យសម្បត្តិរដ្ឋនៅក្រៅប្រទេស

**មាត្រា៤៦ .-**

ការទិញ ការលក់ ការដូរ ឬការជួលទ្រព្យសម្បត្តិរដ្ឋនៅក្រៅប្រទេស ដែលស្ថិតក្រោមការកាន់កាប់និងប្រើប្រាស់របស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះលើកលែងតែមានកិច្ចព្រមព្រៀង សន្ធិសញ្ញាអន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ ឬបទប្បញ្ញត្តិច្បាប់នៃប្រទេស ដែលទ្រព្យសម្បត្តិនោះតាំងនៅ។

**មាត្រា៤៧ .-**

រាជរដ្ឋាភិបាល អាចប្រគល់សិទ្ធិជូនរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងការសម្រេចលើការទិញ ការលក់ ការដូរ ឬការជួលទ្រព្យសម្បត្តិរដ្ឋនៅក្រៅប្រទេស តាមសំណើរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អាចធ្វើការជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យ បន្ទាប់ពីមានការយល់ព្រមពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

រាជរដ្ឋាភិបាល អាចបង្កើតគណៈកម្មការចំពោះកិច្ចដែលដឹកនាំដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោយមានការចូលរួមពីតំណាងអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យនិងសម្រេច ឬស្នើសុំការសម្រេចពីនាយករដ្ឋមន្ត្រី ចំពោះការទិញ ការលក់ ការដូរទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុនៅក្រៅប្រទេស។

**មាត្រា៤៨ .-**

វិធាននិងនីតិវិធីនៃការទិញ ការលក់ ការដូរ ឬការជួលទ្រព្យសម្បត្តិរដ្ឋនៅក្រៅប្រទេស ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៤
## បដិទាន

**មាត្រា៤៩ .-**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលត្រូវបានបដិទាន ដោយហេតុផលស្របច្បាប់ឬដោយការកាន់កាប់ខុសច្បាប់ពីបុគ្គលឯកជន ត្រូវឆ្លងកាត់ការធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិនិងចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋជាមុនសិន មុននឹងដាក់ជាកម្មវត្ថុនៃការលក់ ការជួល ប្រទានកម្ម ការផ្តល់សិទ្ធិផលុបភោគ ការផ្តល់សម្បទានដីសង្គមកិច្ច ការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬការអនុញ្ញាតឱ្យប្រើប្រាស់ក្នុងទម្រង់ផ្សេងៗទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

**មាត្រា៥០ .-**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលត្រូវបានបដិទានដោយហេតុផលស្របច្បាប់ឬដោយការកាន់កាប់ខុសច្បាប់ពីបុគ្គលឯកជន មិនអាចជាកម្មវត្ថុនៃការលក់ ការដូរ ការជួលរយៈពេលវែង ការផ្តល់សម្បទានដី ឬការផ្តល់កម្មសិទ្ធិ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលត្រូវបានបដិទាន អាចជាកម្មវត្ថុនៃការជួលដែលមានរយៈពេលមិនលើសពី១៥(ដប់ប្រាំ)ឆ្នាំ ឬការផ្តល់សិទ្ធិផលុបភោគ ឬការធ្វើអនុប្បយោគ។

**មាត្រា៥១ .-**

វិធាននិងនីតិវិធីនៃបដិទាន ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៥
## សម្បទានដីរដ្ឋ

**មាត្រា៥២ .-**

ដីរដ្ឋ អាចជាកម្មវត្ថុនៃការផ្តល់សម្បទានដី ដែលរួមមានសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ច។

សម្បទានដីសេដ្ឋកិច្ច ជាយន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាមួយជាក់លាក់ទៅឱ្យសម្បទានិកដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្មនិងកសិឧស្សាហកម្ម។

សម្បទានដីសង្គមកិច្ច ជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់ ក្នុងគោលបំណងសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅឋាននិង/ឬធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

**មាត្រា៥៣ .-**

សម្បទានដីសេដ្ឋកិច្ច មិនត្រូវមានរយៈពេលលើសពី៥០(ហាសិប)ឆ្នាំឡើយ។

សម្បទានដីសេដ្ឋកិច្ច មានទំហំច្រើនបំផុតមិនលើសពី១០ ០០០(ដប់ពាន់)ហិកតា។ បុគ្គលម្នាក់ អាចទទួលបានសម្បទានដីសេដ្ឋកិច្ចច្រើនកន្លែង ប៉ុន្តែទំហំផ្ទៃដីសម្បទានសរុបមិនត្រូវលើសពី១០ ០០០(ដប់ពាន់)ហិកតាឡើយ។

ត្រូវហាមឃាត់ការផ្តល់សម្បទានដីសេដ្ឋកិច្ចច្រើនកន្លែងឱ្យបុគ្គលតែម្នាក់ឬឱ្យនីតិបុគ្គលច្រើនប៉ុន្តែគ្រប់គ្រងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដដែលៗ ដែលមានទំហំសរុបធំជាងទំហំដែលបានកំណត់នៅកថាខណ្ឌខាងលើនេះ។

**មាត្រា៥៤ .-**

សម្បទានដីសេដ្ឋកិច្ច ពុំបង្កើតនូវសិទ្ធិកម្មសិទ្ធិលើដី ជូនដល់សម្បទានិកឡើយ លើកលែងសម្បទាន ដីសង្គមកិច្ច។

សម្បទានដីសេដ្ឋកិច្ច អាចជាកម្មវត្ថុនៃសន្តតិកម្ម សម្រាប់រយៈពេលដែលនៅសល់។

សម្បទានិក ត្រូវទទួលខុសត្រូវចំពោះទំហំដីដែលបានប្រគល់ជូន ដូចមានចែងក្នុងកិច្ចព្រមព្រៀង។ ករណីមានការបាត់ទំហំដីដូចមានចែងក្នុងកិច្ចព្រមព្រៀង សម្បទានិកត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**មាត្រា៥៥ .-**

វិធាននិងនីតិវិធីនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៦

## សម្បទានសេវាសាធារណៈ

**មាត្រា៥៦ .-**

សម្បទានហេដ្ឋារចនាសម្ព័ន្ធ ជាសម្បទានដែលមានទំនាក់ទំនងនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធ ជាអាទិ៍៖

- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី
- ហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធដឹកជញ្ជូន មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ផ្លូវដែក ព្រែកជីក
- ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្ភារៈបម្រើឱ្យគម្រោងផ្នែកទេសចរណ៍ មានជាអាទិ៍ រមណីយដ្ឋាន ទេសចរណ៍ សារមន្ទីរ
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យឧស្ម័ននិងប្រេង មានជាអាទិ៍ បំពង់បង្ហូរប្រេងនិងឧស្ម័ន
- ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ
- ប្រព្រឹត្តិកម្មនិងការគ្រប់គ្រងសំណល់
- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យកីឡា
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យតំបន់សេដ្ឋកិច្ចពិសេសនិងលំនៅឋានសង្គម
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យប្រព័ន្ធធារាសាស្ត្រនិងការងារកសិកម្ម
- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈផ្សេងទៀត ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសម្បទានជាធរមាន។

វិធាននិងនីតិវិធីនៃការផ្តល់ ការគ្រប់គ្រង និងការត្រួតពិនិត្យសម្បទានហេដ្ឋារចនាសម្ព័ន្ធ ត្រូវកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៥៧ .-**

សម្បទានគ្រប់គ្រងសេវាសាធារណៈ ជាការប្រគល់សិទ្ធិជូនដល់បុគ្គលឯកជនដើម្បីធ្វើអាជីវកម្មលើទ្រព្យសម្បត្តិរដ្ឋ ឬសេវាសាធារណៈ ដែលពុំមែនជាសេវាអធិបតេយ្យរបស់រដ្ឋ ក្នុងគោលដៅបម្រើសេវាសាធារណៈជូនសាធារណជនប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។

ប្រភេទសេវាសាធារណៈ ដែលអាចធ្វើជាកម្មវត្ថុសម្បទានគ្រប់គ្រងសេវាសាធារណៈ មានជាអាទិ៍ ផ្សារ កំពង់ចម្លង ចំណតរថយន្ត ចំណតជលយាន មជ្ឈមណ្ឌលបែងចែកផលនេសាទ សត្តឃាតដ្ឋាន ទីកន្លែងដាក់សំរាម សេវាអនាម័យ និងសេវាការរៀបចំសណ្តាប់ធ្នាប់សាធារណៈ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

**មាត្រា៥៨ ._**

ការផ្តល់សម្បទានគ្រប់គ្រងសេវាសាធារណៈ មិនត្រូវមានរយៈពេលលើសពី១៥ឆ្នាំឡើយ។

វិធាននិងនីតិវិធីនៃការផ្តល់ ការគ្រប់គ្រង និងការត្រួតពិនិត្យសម្បទានគ្រប់គ្រងសេវាសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៧
## ការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៥៩ ._**

ប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ ធ្វើឡើងតាមរយៈការសម្តែងឆន្ទៈរបស់រដ្ឋប្រគល់ជូនបុគ្គលឯកជននូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងចលនវត្ថុនិង/ឬអចលនវត្ថុ ដោយមិនយកថ្លៃក្នុងហេតុផលសេដ្ឋកិច្ចនិងសង្គម។

**មាត្រា៦០ ._**

ការធ្វើប្រទានកម្មទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាចលនវត្ថុ ត្រូវអនុវត្តតាមវិធាននិងនីតិវិធី ដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

ការធ្វើប្រទានកម្មទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាអចលនវត្ថុ ត្រូវធ្វើឡើងតាមរយៈសម្បទានដីសង្គមកិច្ច ដូចចែងក្នុងផ្នែកទី៥នៃជំពូកទី៦នៃច្បាប់នេះ។

## ផ្នែកទី៨
## ការជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៦១ ._**

ទ្រព្យសម្បត្តិរដ្ឋ ជាចលនវត្ថុនិងអចលនវត្ថុ អាចជាកម្មវត្ថុនៃការជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋក្នុងករណីទ្រព្យសម្បត្តិរដ្ឋស្ថិតក្នុងស្ថានភាពណាមួយ ដូចខាងក្រោម៖

- ត្រូវបានចាត់ចែង ជាអាទិ៍ លក់ ដូរ ប្រទានកម្ម ឬ
- បាត់បង់ ខូចខាតធ្ងន់ធ្ងរ ចាស់ទ្រុឌទ្រោមប្រើប្រាស់លែងកើត ឬ
- បាត់បង់ ខូចខាតធ្ងន់ធ្ងរ ដោយមូលហេតុប្រធានស័ក្តិ។

វិធាននិងនីតិវិធីនៃការជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៩
## ចំណូលពីការគ្រប់គ្រងនិងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៦២ ._**

ចំណូលពីការគ្រប់គ្រងនិងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវបង់ចូលគណនីទោលរបស់ធនាគារជាតិឬគណនីរបស់ធនាគារដៃគូ ដោយមិនអាចដកចំណូលនេះមួយផ្នែកណា យកទៅកាត់កងដោយត្រង់ជាមួយចំណាយ ឬរក្សាទុកបានឡើយ។

វិធាននិងនីតិវិធីនៃការបង់ចំណូលពីការគ្រប់គ្រងនិងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៣ ._**

ចំណូលពីការគ្រប់គ្រងនិងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ អាចត្រូវបានបែងចែកជាប្រយោជន៍ដល់ថ្នាក់ក្រោមជាតិតាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ផ្នែកទី១០
## ភាតពកិច្ចសារពើពន្ធលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៦៤ ._**

រាល់ប្រតិបត្តិការនានាដែលមានកំណត់ក្នុងច្បាប់នេះ ជាអាទិ៍ ការជួល ការលក់ ការដូរ ប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ សម្បទានដីរដ្ឋ សម្បទានហេដ្ឋារចនាសម្ព័ន្ធ និងសម្បទានគ្រប់គ្រងសេវាសាធារណៈ ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៧
## សេវភាពសេវាសាធារណៈ

**មាត្រា៦៥ ._**

សេវភាពសេវាសាធារណៈ គឺជាបន្ទុកដែលដាក់ទៅលើដីមួយហៅដីបម្រើ ដែលតម្រូវជាកាតព្វកិច្ចឱ្យកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិប្រតិបត្តិតាម ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ឬផ្តល់សេវាសាធារណៈ ឬដើម្បីធានាដល់ការការពារ ឬអភិរក្សសម្បត្តិបេតិកភណ្ឌ តំបន់ការពារធម្មជាតិ ឬតំបន់អភិរក្សធនធានធម្មជាតិ ឬធានាដល់ការការពារ ឬអភិរក្សទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដទៃទៀត។

សេវភាពសេវាសាធារណៈ មានលក្ខណៈជាបទបញ្ញាពិសេសដែលកម្រិតសិទ្ធិកម្មសិទ្ធិករឬម្ចាស់សិទ្ធិ លើការកាន់កាប់និងប្រើប្រាស់ដី។ សេវភាពសេវាសាធារណៈនេះ ត្រូវបានកំណត់ជាអាទិ៍ ជាទំហំវង្វង់គិតពីអង្គត់ផ្ចិតនៃទីតាំងតំបន់ដែលត្រូវការពារឬអភិរក្ស ទំហំទទឹង កម្ពស់គិតចាប់ពីការដាំដើមឈើ ឬសំណង់ផ្សេងៗ។

សេវភាពសេវាសាធារណៈ អាចមានលក្ខណៈបណ្តោះអាសន្នឬអចិន្ត្រៃយ៍។

**មាត្រា៦៦ ._**

សេវភាពសេវាសាធារណៈដែលមានលក្ខណៈបណ្តោះអាសន្ន ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ការងារស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ សេវភាពនេះ ត្រូវអស់សុពលភាពនៅពេលដែលការងារកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានបញ្ចប់។

ក្នុងករណីមិនមានការខូចខាតឬមានការខូចខាតតិចតួចដល់ដីបម្រើ កម្មសិទ្ធិករ ឬម្ចាស់សិទ្ធិមិនអាចទាមទារការប៉ះប៉ូវ ឬសំណងឡើយ។

ក្នុងករណីមានការខូចខាតធ្ងន់ធ្ងរដល់ដីបម្រើ អ្នកទទួលផលប្រយោជន៍ពីសេវភាពសេវាសាធារណៈនេះ ត្រូវទទួលខុសត្រូវសងការខូចខាតដល់កម្មសិទ្ធិករឬដល់ម្ចាស់សិទ្ធិ ដែលជាអ្នករងនូវសេវភាពនេះ។

សេវភាពសេវាសាធារណៈដែលមានលក្ខណៈបណ្តោះអាសន្ននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៦៧ ._**

សេវភាពសេវាសាធារណៈដែលមានលក្ខណៈអចិន្ត្រៃយ៍ ត្រូវបានបង្កើតឡើង ក្នុងគោលបំណងការពារ ឬអភិរក្សទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

កម្មសិទ្ធិករឬម្ចាស់សិទ្ធិ ដែលរងនូវសេវភាពនេះ ត្រូវទទួលបានសំណងសមរម្យនិងយុត្តិធម៌តាមបទប្បញ្ញត្តិច្បាប់ស្តីពីអស្សាមិករណ៍។

សេវភាពសេវាសាធារណៈដែលមានលក្ខណៈអចិន្ត្រៃយ៍នេះ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះមហាក្សត្រ

**មាត្រា៦៨ .-**

ក្នុងគោលដៅសណ្តាប់ធ្នាប់សាធារណៈនិងជាប្រយោជន៍ដល់សាធារណជន ជាពិសេសសុវត្ថិភាពរបស់អ្នកថ្មើរជើង អាជ្ញាធរមានសមត្ថកិច្ច ត្រូវដាក់សេវភាពសេវាសាធារណៈលើផ្លូវថ្នល់ទាំងអស់រួមទាំងផ្លូវថ្នល់របស់ឯកជន។

អាជ្ញាធរមានសមត្ថកិច្ច អាចធ្វើការកំណត់ទំហំផ្លូវសម្រាប់អ្នកថ្មើរជើងទៅតាមតម្រូវការនិងទីតាំងជាក់ស្តែង។

## ជំពូកទី៨
## កិច្ចការពារទ្រព្យសម្បត្តិរដ្ឋនិងការលើកទឹកចិត្ត
## ផ្នែកទី១
## ភារកិច្ចការពារទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៦៩ .-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិនិងកាតព្វកិច្ចថែរក្សានិងការពារទ្រព្យសម្បត្តិរដ្ឋ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិប្តឹងឬរាយការណ៍ទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ឱ្យបានទាន់ពេលវេលា ចំពោះសកម្មភាពរំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់និងអំពើដែលបង្កអន្តរាយដល់ទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៧០ .-**

បុគ្គលដែលបានរំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាអចលនទ្រព្យដោយខុសច្បាប់ ត្រូវបង្ខំឱ្យចាកចេញជាបន្ទាន់ដោយគ្មានសិទ្ធិទាមទារសំណងឬការចំណាយលើការងារកែលម្អដែលខ្លួនបានធ្វើលើទ្រព្យសម្បត្តិនោះឡើយ។

**មាត្រា៧១ .-**

ត្រូវចាត់ទុកជាការរំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាអចលនទ្រព្យដោយខុសច្បាប់ ចំពោះអំពើជាអាទិ៍៖

- រាល់ការចូលកាន់កាប់អចលនទ្រព្យរបស់រដ្ឋ ជាភោគៈក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន
- រាល់ការកាន់កាប់ជាភោគៈនៅលើអចលនទ្រព្យរបស់រដ្ឋដែលត្រូវបានកំណត់រួចហើយ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទោះជាមុន ឬក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន
- រាល់ការបន្តកាន់កាប់អចលនទ្រព្យរបស់រដ្ឋក្រោយពេលលិខិតអនុញ្ញាតឬកិច្ចសន្យាឱ្យប្រើប្រាស់ដីអស់សុពលភាពហើយអ្នកកាន់កាប់មិនបានសុំបន្តសុពលភាពត្រឹមត្រូវតាមនីតិវិធីជាធរមាន
- រាល់ការកាន់កាប់អចលនទ្រព្យរបស់រដ្ឋលើសទំហំឬខុសទីតាំងដែលកំណត់ក្នុងលិខិតអនុញ្ញាតឬកិច្ចសន្យាឱ្យប្រើប្រាស់
- រាល់ការផ្ទេរសិទ្ធិប្រើប្រាស់អចលនទ្រព្យរបស់រដ្ឋដោយបំពានលក្ខខណ្ឌក្នុងលិខិតអនុញ្ញាតឬកិច្ចសន្យា
- រាល់ការបំប្លែងការកាន់កាប់អចលនទ្រព្យរបស់រដ្ឋទៅជាកម្មសិទ្ធិឯកជនដោយខុសច្បាប់ មានជាអាទិ៍ ការបន្លំធ្វើបណ្ណកម្មសិទ្ធិលើដីសម្បទានដីសេដ្ឋកិច្ច ឬលើដីដែលទទួលបានត្រឹមការអនុញ្ញាតឱ្យប្រើប្រាស់ ឬធ្វើអាជីវកម្ម ឬការបំប្លែងដីដែលត្រូវបានកំណត់ជាដីសាធារណៈរបស់រដ្ឋ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ មានកាតព្វកិច្ចទាមទារយកអចលនទ្រព្យរបស់រដ្ឋមកវិញ ដោយឥតលក្ខខណ្ឌស្របតាមនីតិវិធី និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

**មាត្រា៧២ .-**

ត្រូវចាត់ទុកជាការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យដោយខុសច្បាប់ ចំពោះអំពើជាអាទិ៍៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- រាល់ការបន្តការកាន់កាប់ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ជាចលនទ្រព្យ ក្រោយពេលលិខិតបទដ្ឋានគតិយុត្ត អនុញ្ញាតឱ្យប្រើប្រាស់អស់សុពលភាព ហើយពុំមានការអនុញ្ញាតឱ្យបន្តសុពលភាពត្រឹមត្រូវតាមនីតិវិធីជាធរមាន
- រាល់ការផ្ទេរការកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាចលនទ្រព្យទៅជាកម្មសិទ្ធិឯកជនដោយខុសច្បាប់ ឬដោយបំពានលក្ខខណ្ឌក្នុងលិខិតបទដ្ឋានគតិយុត្តអនុញ្ញាត។

**មាត្រា៧៣ ._**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ មានកាតព្វកិច្ចថែរក្សានិងការពារទ្រព្យសម្បត្តិរដ្ឋ ដោយត្រូវចាត់វិធានការគ្រប់រូបភាព ដើម្បីទប់ស្កាត់ឬបង្ក្រាបសកម្មភាពកេងប្រវ័ញ្ច ក្លែងបន្លំ រំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬអំពើដែលបង្កអន្តរាយដល់ទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៧៤ ._**

ធនធានរ៉ែដែលស្ថិតនៅលើដីនិងក្រោមដីដែលគ្រប់គ្រងនិងកាន់កាប់ស្របច្បាប់ដោយបុគ្គលឯកជន ឬជាកម្មសិទ្ធិករ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ។

រដ្ឋអាចទាញយកធនធានរ៉ែទាំងអស់ដែលស្ថិតនៅលើដីនិងនៅក្រោមដី ដែលគ្រប់គ្រងនិងកាន់កាប់ស្របច្បាប់ដោយបុគ្គលឯកជនឬជាកម្មសិទ្ធិករ ដោយត្រូវដោះស្រាយជាមួយបុគ្គលឯកជនឬកម្មសិទ្ធិករ អនុលោមតាមបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធអស្សាមិករណ៍ឬច្បាប់ពាក់ព័ន្ធការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ។

**មាត្រា៧៥ ._**

សម្បត្តិបេតិកភណ្ឌវប្បធម៌ ជាអាទិ៍ បដិមា ចម្លាក់ក្រឡោត បុរាណវត្ថុ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលបុគ្គលគ្រប់រូបរួមទាំងកម្មសិទ្ធិករនៃដី មិនអាចអះអាងនូវកម្មសិទ្ធិលើសម្បត្តិបេតិកភណ្ឌវប្បធម៌ ដែលរកឃើញនៅក្នុងដីរបស់ខ្លួនឡើយ។ បុគ្គលគ្រប់រូប រួមទាំងកម្មសិទ្ធិករនៃដី ដែលបានរកឃើញវត្ថុទាំងនេះ មានកាតព្វកិច្ចការពារ និងប្រគល់ឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឬអាជ្ញាធរមានសមត្ថកិច្ច។

ការគ្រប់គ្រងសម្បត្តិបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ផ្នែកទី២
## ភាពព្វកិច្ចការពារផលប្រយោជន៍រដ្ឋនៅចំពោះមុខស្ថាប័នតុលាការ

**មាត្រា៧៦ ._**

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង/ឬអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវតាំងខ្លួនជាភាគីបណ្ដឹងដើម្បីការពារប្រយោជន៍សាធារណៈ សេដ្ឋកិច្ច និងសង្គម ដោយមានកិច្ចសហការពីបុគ្គលពាក់ព័ន្ធចំពោះបណ្ដឹង ដែលស្ថិតក្រោមស្ថាប័នតុលាការទាំងអស់ដែលមានកម្មវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។

## ផ្នែកទី៣
## ការលើកទឹកចិត្តក្នុងវិស័យទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៧៧ ._**

បុគ្គលគ្រប់រូប ដែលបានរកឃើញទ្រព្យសម្បត្តិជាសម្បត្តិបេតិកភណ្ឌវប្បធម៌ឬទ្រព្យសម្បត្តិផ្សេងទៀត ដែលមានតម្លៃជាប្រវត្តិសាស្ត្រ ត្រូវទទួលរង្វាន់លើកទឹកចិត្ត ដោយផ្អែកតាមការព្រមព្រៀងឬតាមការវាយតម្លៃរបស់អ្នកជំនាញ។

វិធាននិងនីតិវិធីនៃការផ្ដល់រង្វាន់លើកទឹកចិត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

### មាត្រា៧៨ .-

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋឬអ្នករាជការសាធារណៈ អាចទទួលបានការលើកទឹកចិត្តជាប្រាក់រង្វាន់ ឬជាបណ្ណសរសើរ ឬគ្រឿងឥស្សរិយយស ឬការដំឡើងឋានន្តរសក្តិ ឬមុខតំណែង ក្នុងករណីដែលបានខិតខំថែរក្សា ការពារ អភិវឌ្ឍទ្រព្យសម្បត្តិរដ្ឋ ឬកៀរគរចំណូលពីការចាត់ចែងទ្រព្យសម្បត្តិប្រកបដោយប្រសិទ្ធភាពនិងវឌ្ឍនភាព។

វិធាននិងនីតិវិធីនៃការត្រួតពិនិត្យ ការវាយតម្លៃ និងការផ្តល់រង្វាន់លើកទឹកចិត្ត ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៩
## អធិការកិច្ចនិងសវនកម្ម

### មាត្រា៧៩ .-

អង្គភាពទទួលបន្ទុកអធិការកិច្ចនិងសវនកម្មនៃក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចាត់វិធានការដើម្បីតាមដាន ត្រួតពិនិត្យ ធ្វើសវនកម្មនិង/ឬអធិការកិច្ចលើការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការគ្រប់គ្រងការប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី១០
## ទោសប្បញ្ញត្តិ

### មាត្រា៨០ .-

អ្នករាជការសាធារណៈឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែលទទួលការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បន្ទាប់ពីទទួលបានដំណឹងអំពីការរំលោភលើកម្មសិទ្ធិនិងសិទ្ធិស្របច្បាប់របស់រដ្ឋលើទ្រព្យសម្បត្តិរដ្ឋដែលព្រងើយកន្តើយដោយមិនចាត់វិធានការតាមផ្លូវច្បាប់ឱ្យទាន់ពេលវេលា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ដល់៣(បី)ឆ្នាំ និងពិន័យជាប្រាក់១ ០០០ ០០០(មួយលាន)រៀល ដល់១០ ០០០ ០០០(ដប់លាន)រៀល។

### មាត្រា៨១ .-

រាល់អំពើរំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាអចលនទ្រព្យដោយខុសច្បាប់ដូចមានចែងក្នុងមាត្រា៧១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ដល់៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០ (បួនលាន)រៀល ដល់ ១០ ០០០ ០០០ (ដប់លាន)រៀល។

### មាត្រា៨២ .-

រាល់ការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាចលនទ្រព្យ ដោយខុសច្បាប់ដូចមានចែងក្នុងមាត្រា៧២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ដល់៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ដល់ ៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

### មាត្រា៨៣ .-

រាល់ការរំលោភបំពាន ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋជាចលនទ្រព្យដោយខុសច្បាប់ ដូចមានចែងក្នុងមាត្រា៧២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ដល់៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ដល់១០ ០០០ ០០០(ដប់លាន)រៀល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះរាជដំណាក់

**មាត្រា៨៤ .–**

អំពើប្រព្រឹត្តដោយចេតនាដោយបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោមឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរដ្ឋ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ ៤ ០០០ ០០០ (បួនលាន)រៀល លើកលែងតែការខូចខាតមានលក្ខណៈស្រាល។

អំពើប្រព្រឹត្តដោយចេតនាដោយបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោមឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរដ្ឋ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ១០ ០០០ ០០០ (ដប់លាន)រៀល កាលបើអំពើនេះបានប្រព្រឹត្តដោយអ្នករាជការសាធារណៈឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត។

**មាត្រា៨៥ .–**

អំពើប្រព្រឹត្តដោយចេតនាដោយបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោមឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរដ្ឋ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ថ្ងៃ ទៅ៦(ប្រាំមួយ)ថ្ងៃ និងពិន័យជាប្រាក់ពី១ ០០០(មួយពាន់)រៀលទៅ១០០ ០០០ (មួយសែន)រៀល ប្រសិនបើការខូចខាតមានលក្ខណៈស្រាល។

**មាត្រា៨៦ .–**

១. នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៨១ មាត្រា៨២ និងមាត្រា៨៣នៃច្បាប់នេះ។

២. នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ៖

ក. ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនិងការជម្រះបញ្ជី)នៃនីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ។

ខ. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

គ. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

ឃ. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

ង. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៨៧ .–**

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នករាជការសាធារណៈឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៨០ ៨១ ៨២ ៨៣ និងមាត្រា៨៤ មិនលើកលែងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសពុករលួយទេក្នុងករណីដែលអ្នករាជការសាធារណៈឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលប្រព្រឹត្តដោយទទួលបានអត្ថប្រយោជន៍ក្នុងការបំពេញមុខងាររបស់ខ្លួនឬក្នុងឱកាសនៃការបំពេញ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មុខងាររបស់ខ្លួនដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ។

**មាត្រា៨៨ .-**

បទល្មើសព្រហ្មទណ្ឌផ្សេងទៀតក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៨៩ .-**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋដែលបានអនុវត្តកន្លងមកត្រូវនៅមានអានុភាពអនុវត្ត រហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមស្មារតីនៃច្បាប់នេះ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៩០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ សៅរ៍ ៤រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០២០

នស/រកម.១១២០.០២២

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# សន្ទានុក្រម

## ក

**ការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ការរៀបចំទ្រព្យសម្បត្តិរដ្ឋក្នុងកិច្ចណាមួយដើម្បីហេតុផលសេដ្ឋកិច្ចជាតិ ដូចជា ការផ្តល់សម្បទានគ្រប់ប្រភេទរបស់រដ្ឋ ការជួល ការលក់ ការដូរ ការធ្វើប្រទានកម្ម បដិទាន និង/ឬការជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

**ការជួលអចិន្ត្រៃយ៍** សំដៅដល់ការជួលអចលនវត្ថុរយៈពេលវែងចាប់ពី១៥(ដប់ប្រាំ)ឆ្នាំឡើងទៅ។

**ការលក់ទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ការលក់ចលនទ្រព្យនិងអចលនទ្រព្យរបស់រដ្ឋ។

**កិច្ចសន្យា** សំដៅដល់កិរិយា ដែលបុគ្គល២នាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។

## ច

**ចលនទ្រព្យរបស់រដ្ឋ** សំដៅដល់គ្រឿងសង្ហារិម មធ្យោបាយ ឧបករណ៍ និងសម្ភារៈប្រើប្រាស់របស់រដ្ឋ រួមទាំងផលរបស់រដ្ឋដែលកើតចេញពីធម្មជាតិនិងការបង្កើតរបស់រដ្ឋ។

## ដ

**ដីព្រៃឈើ** សំដៅដល់ដីក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិ ព្រមទាំងវាលស្មៅ ទោះបីដុះដោយធម្មជាតិ ដោយដាំ ឬដីដែលបានបំប្លែងពីគម្របព្រៃឈើ នៅក្នុងតំបន់ការពារធម្មជាតិឬតំបន់ព្រៃឈើ។

**ដីសាធារណៈរបស់រដ្ឋ** សំដៅដល់ដីដែលដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំរួច ឬដីដែលមានជាប់ផលប្រយោជន៍សាធារណៈ ឬជាដីដែលមានការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈទូទៅ។

**ដីឯកជនរបស់រដ្ឋ** សំដៅដល់ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋនិងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬមិនមែនជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១។

## ទ ធ ន

**ទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត ព្រមទាំងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត អាចហៅនិងសរសេរក្នុងទម្រង់ខ្លីបានជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត អាចហៅនិងសរសេរក្នុងទម្រង់ខ្លីបានជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត** សំដៅដល់ទ្រព្យសម្បត្តិទាំងឡាយដែលដាក់ឱ្យប្រើប្រាស់ដោយផ្ទាល់ដល់សាធារណជន ឬជាតម្រូវការផលប្រយោជន៍សាធារណៈ ឬជាតម្រូវការនៃការផ្តល់សេវាសាធារណៈ និងមានរបបគតិយុត្តការពារពិសេស ពោលគឺទ្រព្យសម្បត្តិនោះ មិនអាចលក់ ដូរ ឬប្រទានកម្ម និងមិនអាចកំណត់អាជ្ញាយុកាលបានឡើយ។

**ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត** សំដៅដល់ទ្រព្យសម្បត្តិទាំងឡាយណាដែលមិនឋិតនៅក្នុងប្រភេទទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ហើយទ្រព្យសម្បត្តិទាំងនោះអាចជាកម្មវត្ថុនៃការលក់ ការដូរ ការធ្វើប្រទានកម្ម ដែលត្រូវគោរពតាមបទប្បញ្ញត្តិនិងនីតិវិធីជាធរមាន។

**ទ្រព្យអនិទាយាទ** សំដៅដល់ទ្រព្យដែលគ្មានទាយាទស្នងមត៌ក។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ធនធានព្រៃឈើ** សំដៅដល់ប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិនិងសិប្បនិម្មិតនៃធនធានរុក្ខជាតិ សត្វព្រៃ ដីព្រៃឈើ និងធនធានធម្មជាតិដទៃទៀតដែលជាសេវាកម្មផ្តល់ដោយព្រៃឈើ។

**ធនធានធម្មជាតិ** សំដៅដល់សមាសធាតុទាំងអស់ដែលឋិតនៅក្នុងដី លើដី ឬក្រោមដី នៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោមបាតសមុទ្រ និងដែនអាកាស ក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាទ្រព្យសម្បត្តិរដ្ឋ។

**ធនធានរ៉ែ** សំដៅដល់ផ្នែកមួយនៃធនធានធម្មជាតិ គឺសារធាតុទាំងឡាយណាទោះក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកើតឡើងដោយធម្មជាតិ តាមដំណើរវិវដ្តភូគព្ភសាស្ត្រឬជាលទ្ធផលនៃការជីកយកពីក្នុងដីលើដីក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ ត្បូងថ្ម ធ្យូងថ្ម រ៉ែលោហៈ ទឹកខនិជ ថ្ម គ្រួស ខ្សាច់ ដីឥដ្ឋ ប្រេងកាត និងឧស្ម័ន។

**នីតិបុគ្គលសាធារណៈដទៃទៀត** សំដៅដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាល អាជ្ញាធរបញ្ញត្តិករ ឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀតរបស់រដ្ឋ។

**ប ផ ព**

**ប្រទានកម្ម** សំដៅដល់កិច្ចសន្យានៃការឱ្យឬការផ្ទេរនូវកម្មសិទ្ធិនៃទ្រព្យសម្បត្តិឯកជន របស់រដ្ឋដោយមិនយកថ្លៃដល់បុគ្គលម្នាក់ឬច្រើននាក់ដែលព្រមទទួលយកទ្រព្យនោះ។

**បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

**បដិទាន** សំដៅដល់ការដកយកមកវិញនូវទ្រព្យសម្បត្តិរដ្ឋឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋវិញ។

**ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត** សំដៅដល់ សមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដើម្បីបំពេញមុខងារសាធារណៈដទៃទៀត។

**ភ**

**ភតិកៈ** សំដៅដល់ភាគីម្ខាងនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ដែលសន្យាថានឹងបង់ថ្លៃឈ្នួលដើម្បីជាថ្នូរនឹងការទទួលបាននូវសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីទ្រព្យសម្បត្តិរដ្ឋណាមួយ ដែលជាកម្មវត្ថុនៃកិច្ចសន្យាជួលនោះ។

**ល**

**លទ្ធកម្មនៃកម្មសិទ្ធិ** សំដៅដល់ការទទួលបាននូវកម្មសិទ្ធិលើទ្រព្យសម្បត្តិណាមួយដោយរដ្ឋ តាមទម្រង់មូលាឬមុធា។

**លទ្ធកម្មនៃកម្មសិទ្ធិតាមទម្រង់មូលា** សំដៅដល់ការទិញ ដូរ និងការទទួលបានតាមរយៈការធ្វើអស្សាមិករណ៍ និងសិទ្ធិបុព្វក្រៃ។

**លទ្ធកម្មនៃកម្មសិទ្ធិតាមទម្រង់មុធា** សំដៅដល់ប្រទានកម្ម អច្ច័យទាន ទ្រព្យនិទាយាទភាព ទ្រព្យអត់ម្ចាស់ បដិទាន ទ្រព្យរឹបអូសដោយសេចក្តីសម្រេចស្ថាពររបស់តុលាការ។

**ស**

**សមុច្ច័យ** សំដៅដល់វត្ថុឬស្នាដៃសិល្បៈដែលមានតម្លៃជាប្រវត្តិសាស្ត្រ វប្បធម៌ អប់រំ សោភ័ណភាព ដែលត្រូវបានប្រមូលមកសន្សំនិងរក្សាទុកដោយមានការកត់ត្រានិងចុះបញ្ជីត្រឹមត្រូវ។

**សិទ្ធិពិសេស** សំដៅដល់សិទ្ធិបុព្វក្រៃ សិទ្ធិអស្សាមិករណ៍ សិទ្ធិលើសេវភាព ព្រមទាំងសិទ្ធិដទៃទៀតដែលមានលក្ខណៈជាបទបញ្ញានិងជាឆន្ទានុសិទ្ធិរបស់រដ្ឋ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**សិទ្ធិបុព្វក្រៃ** សំដៅដល់សិទ្ធិដែលមានចែងក្នុងច្បាប់ឬកិច្ចសន្យាដោយស្ម័គ្រចិត្ត ក្នុងការផ្តល់ឱ្យទៅនីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនទទួលបាននូវសិទ្ធិដំបូងគេក្នុងការទិញអចលនទ្រព្យបម្រើឱ្យផលប្រយោជន៍សាធារណៈ ក្នុងករណីដែលម្ចាស់កម្មសិទ្ធិយល់ព្រម។

**សេវាសាធារណៈ** សំដៅដល់រាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន និងធ្វើឡើងដោយផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិនិងភារកិច្ចពីរដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋឬភ្នាក់ងាររដ្ឋក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។

**សម្បទានសេវាសាធារណៈ** សំដៅដល់ការប្រគល់សិទ្ធិរបស់រដ្ឋទៅឱ្យបុគ្គលឯកជនក្នុងការផ្គត់ផ្គង់សេវាសាធារណៈដោយផ្ទាល់ឬដោយប្រយោលដើម្បីជាប្រយោជន៍សាធារណៈ តាមរយៈការសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធនានា ឬតាមរយៈការផ្តល់សិទ្ធិជូនបុគ្គលឯកជនលើការធ្វើអាជីវកម្មលើទ្រព្យសម្បត្តិរដ្ឋ ឬលើសេវាសាធារណៈដែលពុំមែនជាសេវាអធិបតេយ្យរបស់រដ្ឋ។ សម្បទានសេវាសាធារណៈ បែកចេញជាសម្បទានហេដ្ឋារចនាសម្ព័ន្ធនិងសម្បទានគ្រប់គ្រងសេវាសាធារណៈ។

**សន្តតិកម្ម** សំដៅដល់ការផ្ទេរសិទ្ធិនិងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។

**សេវភាពសេវាសាធារណៈ** សំដៅដល់បន្ទុកដែលដាក់លើដីមួយហៅដីបម្រើ ដែលតម្រូវជាកាតព្វកិច្ចឱ្យកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិប្រតិបត្តិតាមក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ឬផ្តល់សេវាសាធារណៈ ឬដើម្បីធានាដល់ការការពារ ឬអភិរក្សសម្បត្តិបេតិកភណ្ឌ តំបន់ការពារធម្មជាតិ ឬតំបន់អភិរក្សធនធានធម្មជាតិ ឬធានាដល់ការការពារ ឬអភិរក្សទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដទៃទៀត។

**សេវភាពសេវាសាធារណៈដែលមានលក្ខណៈអចិន្ត្រៃយ៍** សំដៅដល់សេវភាពសេវាសាធារណៈ ដែលតម្រូវឱ្យកម្មសិទ្ធិករឬម្ចាស់សិទ្ធិលះបង់នូវកម្មសិទ្ធិលើអចលនវត្ថុរបស់ខ្លួនជូនរដ្ឋ មិនមានកាលកំណត់និងជាស្ថាពរដោយរដ្ឋត្រូវផ្តល់សំណងសមរម្យនិងយុត្តិធម៌ជូនកម្មសិទ្ធិករឬម្ចាស់សិទ្ធិ។

**សេវភាពសេវាសាធារណៈដែលមានលក្ខណៈបណ្តោះអាសន្ន** សំដៅដល់សេវភាពសេវាសាធារណៈ ដែលតម្រូវឱ្យកម្មសិទ្ធិករឬម្ចាស់សិទ្ធិលះបង់នូវកម្មសិទ្ធិលើអចលនវត្ថុរបស់ខ្លួនជូនរដ្ឋក្នុងកាលកំណត់ណាមួយរហូតដល់សេវភាពនេះត្រូវបានបញ្ចប់ ទើបកម្មសិទ្ធិករឬម្ចាស់សិទ្ធិទទួលបានសិទ្ធិលើអចលនវត្ថុរបស់ខ្លួនវិញ។

**ស្ថានតំណាង** សំដៅដល់ស្ថានឯកអគ្គរាជទូតនិងស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការតំបន់ និងអង្គការអន្តរជាតិ ស្ថានអគ្គកុងស៊ុល ស្ថានកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយស។

៚

**អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងគ្រប់គ្រង តាមដាន និងត្រួតពិនិត្យលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

**អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិនិងនីតិបុគ្គលសាធារណៈដទៃទៀត ដែលកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ។

**អចលនទ្រព្យរបស់រដ្ឋ** សំដៅដល់អចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា និងអចលនវត្ថុតាមការកំណត់របស់ច្បាប់។

**អ្នករាជការសាធារណៈ** សំដៅដល់៖

ក. បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការ ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្តទោះជាអចិន្ត្រៃយ៍ឬជាបណ្តោះអាសន្នក្តី ទោះជាបានឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈអាយុរបស់បុគ្គលនោះឡើយ។

ខ. បុគ្គលឯទៀតដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**អនុប្បយោគ** សំដៅដល់ការផ្លាស់ប្តូរប្រភេទទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**អធិប្បយោគ** សំដៅដល់ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ មកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

**អច្ច័យទាន** សំដៅដល់ប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។

**អនុប្បទាន** សំដៅដល់ការផ្ទេរសិទ្ធិឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយីទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។

**អស្សាមិករណ៍** សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុឬសិទ្ធិប្រត្យក្ស លើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ រួមមានដី សំណង់ និងដំណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដែលបម្រើប្រយោជន៍សាធារណៈនិងផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុន ដោយសមរម្យនិងយុត្តិធម៌។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *